ខ្លះខ្ចីខ្លះទុំ ខ្លះទើបក្រពុំ រីករោយបុប្ផា
ពិដោរល្ហុយល្ហប់ សាយសព្វទិសា ខ្លះជ្រុះផលា
ដោកដាំនៅដី ។

ព្រះពង្សពុទ្ធា យង់យល់ផលា ទឹកដល់ក្សត្រី
ជាទប្អូនស្ងួន ខ្ញុំខ្លួនពិសី ឃ្លាតទៅទូរទី
តំបន់ឋានឆ្ងាយ ។

នាងនៅនេះក៏ នឹងបេះផលា បរិភោគសប្បាយ
ពីនាក់នឹងស្ងួន ខ្ញុំខ្លួនពណ្ណកាយ ដើរលេងនិយាយ
ក្រសាលក្សេមក្សាន្ត ។

ឥឡូវប្អូនឃ្លាត បងខំសង្វាត ត្រាច់តាមដោយដាន
យល់ផលពិសី នឹងធីពុំបាន ផ្អែកផ្អូនពុំឃ្លាន
មិនបង់កោក្តា ។

អ្នកខ្ញុញបណ្តើរ ដោយផ្លូវដំណើរ វែងខំយាត្រា
ស្រគត្រូតពេកពន់ ទន់ៗសុរិយា ដល់ឆ្នេរជលសា
សមុទ្រជោរជល ។

ទំហំ១០០យោជន៍ លង្ហឹមលង្ហោច ប្រាំងត្រើយពុំយល់



ទើបអ្នកឈប់ខាន សម្រាន្តកាយពល នៅនាមណ្ឌល
ម្លប់ព្រឹក្សាសាយ ។

អ្នកគិតថប់ថា ហៃសុនខា សស្ងុតពណ្ណកាយ
សមុទ្រនេះធំ ទំហំសោកឆ្ងាយ មើលទៅពីអាយ
បាត់ត្រើយពុំយល់ ។

យើងនឹងហែលឆ្លង ម្រាំងរួចរលង អំពីក្នុងជល–
សាសមយើងក្សយ ប្រល័យសូន្យសល់ ពិតពុំបានដល់
ត្រើយត្រាណដូចប៉ង ។

ឧប្អូនកល្យាណ ម៉េះសមពុំបាន ដល់ដូចបំណង
សមនឹងឃ្លាតឃ្លា កាលគ្រានេះម្តង ដៀតនឹងហែលឆ្លង
ទឹកទៅពុំបាន ។

ឧប្អូនព្រលឹង ម៉េះសមទន្ទឹង ក្នុងចិត្តគិតស្មាន
ជាបងតាមទៅ ដល់ពៅកល្យាណ មិនដឹងជាខាន
នៅឆ្នេរជលសា ។

សុនខចាស់ឆ្លើយ ជាអម្ចាស់អើយ កុំព្រួយចិន្តា
កាលនាងនឹងទៅ ផ្តាំទូលខ្ញុំថា សមុទ្រជលសា

នេះពកតុំជ្រៅ ។

ល្មមដើរធ្ងងបាន ហែលខ្លះដោយដាន អន្ទង់ជំរៅ

យប់នេះម្ចាស់ខាន សម្រាន្តនិត្យទៅ ព្រឹកឡើងធ្ងន់ទៅ

ឲ្យដល់ត្រើយត្រាណ ។

ពោធិសត្វស្តាប់ សុនខប្រាយប្រាប់ អ្នកជីងដោយដាន

ពាក្យពីនានផ្តាំ ថៃតាំមិញមាន ហច្ចយស្រាកស្រាន្ត

ស្រនស្រាលទុក្ខា ។

អ្នកផ្ទុំយប់នោះ ព្រឹកឡើងចរចុះ ទៅក្នុងជលសា

ដើរខ្លះហែលខ្លះ រូតរះយាត្រា ឯសុនខា

ហែលតាមទៅផង ។

ក្នុងជលសាគរ មច្ឆាវិករ ក្រាស់ក្រែកខ្ទង់.

លៀសឆាវគ្រែងគ្រំ កំរម្យខ្លៅខ្យង បង្គាបង្កង

ចបទៀបតាក់ប្រែង ។

មានត្រីក្តាំងហាយ ក្តាំងហាតកន្លាយ កន្ធរអណ្តង

អណ្តាតឆ្កែខ្ចឹង ថែងក្រែងដងខ្លង ឆ្កោកក្តាប្រកែង

ផ្កាបារសណ្តាយ ។



ក្រហែក្រហោ ក្រមាល់ទំពោ ក្រឹមក្រាញក្រុសក្រាយ

ក្រឡុនក្រសក់ អាចម៍កុកក្រឹមសាយ ឆ្តោសំពុះបាយ

អំពិលទុំទុក ។

ព្រលូងប៉ាអៀវ គ្រែងគ្រំកំភ្លៀវ កំភ្លាញកំភ្លុក

អង្កត់ប្រាក់ប្រា គជ្រោះផ្លុងផ្លក់ ក្អិតក្អីក្អែកក្អុក

ឈោតចឹកបង្ហា ។

កញ្ចុះកញ្ឆក- ស្វាស្វាតត្រីប្រាក់ ត្រីព្រួលត្រីខ្វា

រមាសប្វាជូ ប៉ាមូប៉ាមា គល់កាំងឹកដក-

ហ៊ូហែលប្រៀវប្រែ ។

កញ្ជ្រូកកញ្ចាញ់- ប្រាសប្រុឡឹងលេញ កន្ត្រប់ដងដៃ

ចង្វាលកែសកែ ស្ពង់មៃជំរ៉ អណ្តើកត្រៃសៃ

ត្រសងហិចហែល ។

ក្រពាត់ក្រពត ក្រពើក្តរផ្សោត ឆ្លាមត្វាំងបៃបែល

ក្សកក្សកខ្វែកឆ្នា ស្បៃកាច្រនៃល កំករកំកល

ពិន្ទង់មករ ។

មុជហែលលីលា លលេញជញ្ជា ដំទឹកខ្លាយខ្ទ

រវាមរវល់ ក្នុងជលសាគរ ក្រាស់ក្រៃរីករាវ

អនេកគណនា ។

ហេតុព្រះបារមី ពន្លកជិនស្រី សពេជ្ញសាស្តា

អស់សត្វសាគរ បៀសបរញ្ញោក ពុំហ៊ានហិង្សា

បៀតបៀនប្រមាថ ។

អ្នកខំហែលឆ្លង ឲ្យរួចរំលង ពីក្នុងជលជាត

សុនខសសឹង ខំប្រឹងសង្វាត ហែលពុំឲ្យឃ្លាត

ពីព្រះពោធិ ។

អស់ឥតកំឡាំង រឹងរួយជើងគាំង ញ័រអស់ឥន្ទ្រិយ

ខំហែលហត់ហើយ ដល់ត្រើយជលធី ក្សណក្ស័យជីវី

ប្របផ្ទៃសាគរ ។

ពន្លកទសពល មៀងមើលយង់យល់ សុនខមិញមរណ៍

អ្នកសែនសោយសោក ទើបយកព្រះករ ទាំងពីរគក់គក

ទុកទួញថា ។

· ឱសុនខអើយ ឥឡូវម្តេចឡើយ បាមកមរណា

ក្សណក្ស័យចាកបេរ ប្របផ្ទៃជលសា ពោលអន្តអញ្ញា(១).

១–អសារ, តែសម្រួលតាមសម្ផស្សកាព្យ ទើបទៅជា អា ។



សារសោះសូន្យសល់ ។

អញសង្វាតមក យាត្រារុករក តាមនាងនិមិល

ហើយហត់លំបាក គោកយាកតាមកល លែងតែបានដល់

យល់នាងនារី ។

សង្ឃឹមតែបា កំដរជាគ្នា ដើរដោយទូទី

ឥឡូវបាក្ស័យ ប្រល័យជីវី តើកម្មពៀរពី

បុពណាទៀងទាត់ ។

ឲ្យអញកណ្តែន កណ្តោចម្នាក់ឯង កណ្តាលព្រៃស្ងាត់

ស្ងៀមស្ងប់ជ្រងំ ទុរគមពេកក្តាត មានតែសព្វសត្វ

កំដរជាគ្នា ។

ឱបាមានចិត្ត ឈឺឆ្អាលអញពិត ពុំដែលឃ្លាតឃ្លា

ដល់មួយពេត្រ ពោះបីយាត្រា ទៅផ្ញើចំការ

បាតាមទៅផង ។

បាមានគំនិត កុំឲ្យព្រួយចិត្ត ដើរកាយដល់ម្តង

យប់ព្រសង់ផ្ទុង ចាំក្នុងបេង មិនឲ្យសត្វផង

ចូលធីដំណាំ ។

ទោះអញពុំទៅ ត្រាច់ដើរលេងទៅ ទុកបាឲ្យចាំ
មើលថានត្រីហារ រក្សាថែទាំ ឥឡូវគឺកម្ម
ឯងឲ្យឃ្លាតឃ្លា ។
អ្នកខ្ញុំសព្វគ្រប់ សោកស្មើរសេទ្ទប់ ស្តាយសុនខា
ខ្សឹកខ្សួលអួលអាក់ ម្ចាស់ម្នាក់ឯងថា ទុក្ខទោមនស្ស
ថ្ងៃថ្ងឹងពុំបាន ។
លុះចូលពគ្រើ អ្នកផ្ទំខាងទី ផ្ទេរផលសាសាទ្ត
ខ្ញុំទៅទេវី ក្សត្រីកល្យាណ ជាធមាសមាន
រូបកាន់សោកា ។
ឥឡូវបងមក តាមប្អូនពន្ទក ឆ្ងាស់ឆ្ងងផលសា
រូបបានដល់គ្រើយ ហើយសុនខា បាត់បង់មរណា
ប្រែបផ្ទេរផលធី ។
ម៉្ល៉ះសមបងខាន កូនព្រៃពុំបាន យល់ប្អូនពិសី
ផ្សិតឥតគនរណា នាំមាគាពី អាយឲ្យដល់ទី
តំបន់ប្អូនភ្នា ។
សមបងវាឆ្ងើង កូនព្រៃកណ្តាន កណ្តាលអង្គា



ម្នាក់ឯងក្សិណក្ស័យ ប្រល័យជន្មា កូនព្រៃព្រឹក្សា
សូន្យសោះអាសារ ។
បងគិតទៅគ្រប់ គ្រប់ហើយរឹងថប់ ថប់ប្អូនប្រការ
ថប់មួយផ្សិតស្ងួន ខ្ទឹមខ្ទួនសង្សារ កំពុងពេញពាល
ប្រាសព្រាត់ឃ្លាតឃ្លា ។
ថប់មួយឥតអ្នក- ណាទឹងចាំជាក់ ដឹងដានមាគ៌ា
នាំនាំផ្លូវទៅ ដល់តៅពុំឆា ឲ្យបានជួបជា
គូគ្នាស្នេហ៍ស្និទ្ធ ។
ថប់មួយគិតស្តាយ សុនខអគ្គពាយ បាត់បង់ជីវិត
រឹងជាកណ្តង ម្នាក់ឯងពេកពិត រឹតរឹងអាណិត
អនាថអនិច្ចា ។
ថប់មួយខ្ទួនបង ដើរត្រាច់ដោយដង ទីទូរអគ្គា
គិតក្រែងពុំដល់ មណ្ឌលប្អូនភ្នា គិតទៅរឹងជា
ថប់ក្តាត់ពេកពន់ ។
ព្រះពោធិសត្វ ពិលាបពេកក្តាត់ ខ្ញុំទៅប្អូនគន់
សម្រេងសង្រែ ហឫទ័យគិតគន់ ខ្សឹកខ្សួលអួលអន់

ក្រៃពេកកន្លង ។

សម្ដេចភគវ បន្ទូលទេសនា ថាហៃភិក្ខុផង
នេះគឺកម្មពៀរ ពុំនៀរចាំបង់ ពុំដែលរំលង
បៀសបាកទុក្ខា ។

កើតក្នុងសង្សារ ដូចនៅកណ្ដាល សមុទ្រជលសា
ពុំដែលបៀសបាក វិបាកកាយា សឹងមានវេរា
ព្រេងមកផ្ដិតផ្ដល់ ។

ក្សិណខ្សត់ក្សណមាន ក្សិណបង់ក្សិណបានយសសក្ដិសុខសល់
ក្សិណព្រាត់ក្សណប្រាស និរាសពុំយល់ សឹងជាទុក្ខទល់
ដូចព្រះធម៌ថា ។

គួរគិតទុក្ខំ គួរគិតអនិច្ចំ គួរគិតអនត្តា
ព្រះត្រៃលក្ខណ៍ញាណប្រទានទុកថា អារម្មការនា
រំពឹងសព្វថ្ងៃ ។

សង្សារពុំសុខ តែងតែមានទុក្ខ នោះទៀងពេកក្រៃ
ក្សិណរស់ក្សិណស្លាប់ ក្រឡាប់វិលវៃ ក្សិណភិតក្សិណភ័យ
ពុំដែលសុខសាន្ត ។



គួរគិតព្រះធម៌ ភាវនាអស់អាថ៌ បូលព្រះកម្មដ្ឋាន
ខែងខំឲ្យដល់ ត្រើយថ្កល់និព្វាន និរទេសមិនមាន
ពោសទុក្ខភ័យមរណ៍ ។

និរជាតិជរា ព្យាធិរោគា ក្រេមក្រាន្តបវរ
បានសួគ៌ទេព កាមាវចរ ពុំស្មើនគរ
និព្វានថ្លាថ្លៃ ។

គេជះសម្ភារ គោគកុលកុមារ ពង្សពុទ្ធញាណញេយ្យ
កក្រើករំជួល ដល់សួគ៌ាល័យ ពិភពបានត្រៃ-
ត្រឹង្សាសួគ៌នាយ ។

អស់ញាតិកា គោគកុលកុមារ ដែលស្លាប់ពីអាយ
យោនយកកំណើត ទៅកើតសួគ៌នាយ សឹងក្ដៅក្រហាយ
និងនៅពុំស្កល់ ។

ប្រែបើកទិព្វចក្ខុ មៀងមើលយល់ជាក់ ជាបៅគោគកុល-
កុមារសោយសោក អមោក្ខទុពិល នៅនាឆ្ពេជល
ជាទុក្ខសល់ខ្នាត ។

ទើបអស់ទេវតា ជុំនុំគិតគ្នា ព្រមប្រើព្រះញាតិ

មួយមកកាឡា  ប្រែជាស្តេចត្មាត  ហោះចុះសង្កាត

ដល់ផ្ទះដេលសា ។

ត្មាតចចូលដល់  ទៅបៅភោគកុល  ទើបស្រដីថា

ខ្ញុំសង្កាតមក  រួសរកប្រាថ្នា  សុំសុនខា

បរិភោគសោះឃ្លាន ។

ព្រះពោធិសត្វ  មហាបុរសេត្ត  ស្តាប់ហើយឆ្លើយថ្កាន

ជាហៃស្តេចត្មាត  សង្កាតរុកពន  ចុះមកចង់បាន

បរិភោគខ្មោចឆ្កែ ។

ខ្ញុំព្រមឲ្យអ្នក  យកបរិភោគភ័ក្ស  ចំអែតតាមតែ

ចំណង់ប្រាថ្នា  អ្នកអាសូរណៃ  នាំផ្លូវទៅឯ

សត្តកុដបុរី ។

ផ្សិតខ្ញុំកំព្រា  ព្រាត់ប្រាសភរិយា  ឃ្លាតទៅទូរទី

ពុំដឹងមាគ៌ា  យាត្រាទៅខ្ញុំ  ចូរអ្នកប្រណី

នាំណៃមាគ៌ា ។

ទើបស្តេចត្មាតឆ្លើយ  ថាអម្ចាស់អើយ  កុំព្រួយចិន្តា

ខ្ញុំនឹងនាំអ្នក  វេលគួណ៌យាត្រា  ថាហើយហាក់ជា



បរិភោគឆ្កែនោះ ។

វិស័យតាមដោយ  បំបាំងមិនឲ្យ  យល់ជាក់ចំពោះ

លុះព្រឹកស្រាងស្រេច  ទើបស្តេចត្មាតនោះ  នាំអ្នកត្រាច់ផ្ដោះ

ដើរដោយមាគ៌ា ។

## បទព្រហ្មគីតិ

កាលនោះពោធិសត្វ  បុរសេត្តថ្លៃសោភា

សីហនាទយានយាត្រា  ត្រាច់ដើរតាមស្តេចត្មាតនោះ ។

ចូលក្នុងព្រៃព្រឹក្សា  ដោយបព្វតាជ្រង់ជ្រោយជ្រោះ

លុះលេចដល់ព្រោះ  យល់សព្វសត្វនៅដោយវាល ។

រមាំង រមាំងមៀង  មើលកាល់កៀងគូត្រអាល

ដីស្មៅនៅកណ្ដាល  វាលរបោះបេបគ្នា ។

រមាស-រមាសដើរ  ដើររមៀងមើលរកបន្ទា

បរិភោគឈរេក  ឈប់ដោយម្លប់ព្រៃផ្គុំ ។

ដំរី-ដំរីស្រប់  ស្រប់ក្រោមម្លប់ដើមឳដុំ

បេះបោចកេចល្ងិន-  ដំរីបានបរិភោគ ។

ក្របី-ក្របីព្រៃ  រកវៃតកៀងគូក

ថ្មូចថ្ងូរកេភោគ  ត្រួយក្របាសក្របៅខ្ញី ។

ទន្សាយ-ទន្សាយសឹង ពាក់ពួនពីងរកចំណី
ប្រិចត្រួយស្មៅខ្ចី ជ្រកក្រោមម្លប់-ម្លប់ទន្សែ ។
ទន្សោង-ទន្សោងសោត ដើរលេងលោតប្រឹងប្រាណប្រែ
ស៊ីស្មៅល្អស់បានបែរ ទៅឈរឈប់ម្លប់ទន្សារ ។
ឆ្កែព្រៃ-ឆ្កែព្រៃព្រើស ដេញទាមប្រើសនៅកណ្តាល
ខាំស៊ីជាអាហារ ហើយទៅឈប់ម្លប់ឆ្កែស្រែង ។
គោព្រៃ-គោព្រៃព្រោះ ដើរចន្ទោះផ្សាយពលវែង
ស៊ីស្មៅហើយលោតលេង នៅក្រោមម្លប់-ម្លប់គោមួយ ។
ចចក-ចចកនៅ ដើមចចៅឈរន្ទួយ
ជ្រូកព្រៃ-ជ្រូកព្រៃព្រួយ ឈ្មុសដីមើមក្រពញជ្រូក ។
ខ្លាធំ-ខ្លាធំក្រាប ក្រាបស្រពាបនៅដម្បូក
គយឃ្លាំចាំចាប់ជ្រូក ផ្អាប់ខាងដើមដើមដៃខ្លា ។
ក្តាន់តាង-ក្តាន់តាងកៀង គូមិត្រមៀងរកភោក្ដា
អណ្តាប់អណ្តោយគ្នា ឈប់នៅម្លប់-ម្លប់ដើមក្តុល ។
ស្វាព្រាម-ស្វាព្រាមព្រៃ ក្អែករវៃរកត័ស្តុផល
ដណ្តើមគ្នារបស់ ស៊ីផ្លែស្វាយ-ស្វាយមីងព្រួល ។



ព្រះពោធិសត្វយល់ សត្វសែនសល់អន់អាក់អួល
ទុកឹងរំជួល គិតទៅដល់វរជាយា ។
ជាទុប្អូនរ័ក្ខ អស់សព្វសត្វកៀងគូព
ដណ្តើមរកភោក្តា ទន្ទឹមចាំងគូឈ្មោលញី ។
ម្តេចឡើយតែបងបង់ ប្អូនវរវង្សពេញពិសី
ឃ្លាឃ្លាតទៅទូរទី មិនមូលមិត្រដូចសព្វសត្វ ។
ទួញភ្លាងយាងយាត្រា កុនព្រឹក្សាសូន្យស្ងប់ស្ងាត់
ប្រាំពីរយោជន៍ទៀងទាត់ លុះព្រលប់ស៊ុរិយោ ។
ចរចូលឈប់សម្រាន្ត នៅក្រោមថានម្លប់ព្រឹក្សា
ឯគ្នាតនោះធ្វើជា មរណ៍ក្សីណក្ស័យដីពជន្មជាតិ ។
ព្រះពោធិនិមិល មៀងមើលយល់ទូរស្តេចគ្នាត
ក្សីណក្ស័យសូន្យសាកសាត អ្នករឹងព្រួយព្រះចិន្តា ។
ទួញទ្រង់ព្រះកន្សែង ពិលាបថ្លែងទំនួញថា
ឱប្អូនទៅពុំផា បាបអ្វីបងឲ្យអក័ត្យ ។
- សង្ស៊ឹមគ្នាតបក្សា នាំយាត្រាត្រាប់ឲ្យធាប
ឥឡូវគ្នាតវិញស្លាប់ សូន្យអសារអសោចសល់ ។

ទុកម្ទារ៉ាកបង តែងឲ្យផែ១ទុក្ខទល់
ឯកអង្គឯងអំពល់ អំពីព្រាត់ប្រាសប្អូនភ្ងា ។
ទុអង្គអញឯកោ អនាថោក្ទងអញ្ហា
ឥតអង្គអ្នកឯណា មួយគ្រាន់ពឹងគ្រាន់អាស្រ័យ ។
មានតែគុណព្រះពុទ្ធ ជាតិជាមកុដតាំងកពាត្រៃ
ទូវព្រះគុណធម៌ថ្លៃ ទូវគុណព្រះអរិយសង្ឃ ។
ជៀសជួយជាទីពឹង ជាទីពឹងទីពំនាក់អង្គ
ទើបនាក់លើកករផ្គង់ ដាក់លើសិរសើស្ញូត្រថា ។
ពុទ្ធោ មេ ណាថោ[1] ឧត្តមោ មង្គលា[2]
ធម្មោ មេ ណាថោ[3] សរណំ មង្គលំ[4]
សង្ឃោ មេ ណាថោ វរោ បុញ្ញក្ខេត្តំ[5]
សព្ពទុក្ខភយំ ភេទា វិណាសន្តុ[6] ។
ពោធិសត្វតាវនា ព្រះធម្មាលុះយាមបី

---

១ – ព្រះពុទ្ធជាទីពឹងរបស់ខ្ញុំ ។ ២ ជាមង្គលខ្ពង់ខ្ពស់បំផុត ។ ៣ បើលៃឲ្យពួនតាមរបៀប កាព្យត្រូវដាក់ថា «ធាថោ»។ ៤ ជាទីពឹងនិងជាមង្គល ។ ជាស្រែបុណ្យដ៏ប្រសើរ ។ ៦ ទុក្ខភ័យនឹងភេទទាំងពួង ចូរវិនាសបាត់បង់ទៅ ។



អ្នកនិទ្រានៅដី លក់លុះស្រាន់ព្រះសុរិយា ។
ទើបទេវបុត្រមួយប្រាណ ជាសន្តានញាតិពង្ស
និម្មិតប្រែអាត្មា ជាក្អែក ១ ហើរមកដល់ ។
ពោលពាក្យស្រដីថា ហៃអ្នកមាណពនិម៌ល
ខ្មោចត្មាតនេះនៅសល់ ខ្ញុំសុំបរិភោគសោះឃ្លាន ។
ព្រះពោធិសត្វឆ្លើយ ថាក្អែកអើយបើអ្នកមាន
ប្រាថ្នាចិត្តចង់បាន បរិភោគខ្មោចត្មាតនោះមិញ ។
យើងព្រមឲ្យអ្នកធី ជាចំណីមិញកុំម្នេញ
ហើយអ្នកជួយនាំអញ ឲ្យដល់សត្តកុដបុរី ។
ក្អែកស្ដាប់ហើយហើរភ្លាម ទៅចំនាន់ត្មាតបក្សី
បំបាំងធ្វើជាធី ស្រេចនាំអ្នកចរយាត្រា ។
ចូលក្នុងព្រៃស្រោងស្រោង សឹងគោងថ្មសិលា
មានទឹកជ្រោះរងថ្លា ដោយមាគ៌ារៀងរាបទៅ ។
អ្នកឈប់ខាងគង្គា ហើយយាត្រាគ្រាចសំដៅ
បរចូលក្នុងព្រៃជ្រៅ យល់សុទ្ធសឹងសត្វបក្សា ។
កៀនគូទាំងឈ្មោលញី ហើរគេសុំគេស្ទុផលា

បណ្ដើរបន្ទើគ្នា    ទំដោយដើមព្រឹក្សាសោត ។
មាក់ដោកប៉ោលគោកទំ    ទំហើយយំហើរលេងលោត
កន្ធាញ់កែសកែកោដ្ឋ    សត្វកន្ធាញកងកេងទំ ។
ក្អែកព្រាប-ព្រាបព្រៃទៅ    រកទំនៅជាទ្រនំ
សេកយា-សេកយាយំ    ហើរទៅទំដើមត្រសេក ។
ឥទ្រើងទ្រើងសំណាក់    ពួនពឹងពាក់ជាដំណេក
ដើងចាប-ចាបព្រៃដេក    ដើមក្រសាំងក្រសារនៅ ។
បេកទុំ-បេកទុំទេស    ដើមការកេសកន្ធត់ខ្មៅ
ទន្ទេងទន្ទាបទៅ    ទំចឹកចាប់ក្ដុកគោក្ដា ។
ទៀនទឹកដើងទៀនទំ    ទំហើយយំកេគូរ
ពញាក់ទំពញា    ដើមនាងនួននាងនួននៅ ។
សសេះ-សសេះសោត    ទំលេងលោតហើយហើរទៅ
ចចាតចាបចចៅ    ដើមមហាហង្ស-ហង្សនៅនិត្យ ។
ផ្ទាលមាន់មាន់ទឹកទៅ    ទាំងគូនៅទំមូលមិត្រ
ដើងគោស្ដុបគោលិត(១)    ទៅទំនៅ-នៅក្ខា ។
ឥឡាក-ឥឡូលោត    ខ្ទៀវខ្ទារសោតកេគោក្ដា

១ តាមវចនានុក្រមខ្មែរជា គួលីត ។



ស្ទែស្ទាប់ស្ទោញរេក    ទំសំកុកសំគាំងស្វាប ។
ដៃខ្លាសត្វទ្រមាក់-    ខ្លាសំណាក់ក្រញូងក្រុងក្រាប
ស្នាំងស្នុះផ្ទះទន្ទាប    ទន្ទេងទៅទំទន្ទា ។
ខ្វែងគង់ខ្វែងស្រាកស្រែក    ទំលើមែករកគូរ
ដើមប្រពេចចង្វា    សត្វប្រពេចទំលោតលេង ។
អាអូត-អាអូតទំ-    ដើមទ្រទំអាអូតឯង
កុកក្រកកុកគ្រាង់ក្រែង    ទំដើមត្រាំងដើមគ្រលគ្រង់ ។
បង្កើបង្ការដេក    ជាដំណេកនៅចំចុង
ទៀបទៀវទាសទន្ទុង    ទុងទោមទៀវទំសម្រាន្ត ។
ក្រក្រាយក្រួចក្រួចក្រៀល    ទំសសៀរសសិតប្រាណ
ដើមមន់ដើមមៀនមាន    សត្វមៀមមុំទំនិត្យនៅ ។
ព្រវកព្រវែកទំ    ទាំងគូយំហើយហើរទៅ
ចាបចៀបក្របាសនៅ    ដើមក្រញៅក្របាសព្រៃ ។
បង្អូរ-បង្អូរគ្នាត    គ្នាតទំព្រាតគយរ៉ៃ
រូសពក់ពេកពាំងរៃ    រៃកណ្ដើងកណ្ដូបយំ ។
រំពេកនៅរំចាក    ចាក្រពាកចាប់ទ្រនំ

សិរមាន់មាន់ទោំ ដើមផ្កាចិន-ចិនលោនៅ ។
ព្រះពន្សពោធិសត្វ គ្រាប់ដើរកាត់គុម្ពព្រៃជ្រៅ
យល់សព្វសត្វនៃបនៅ ទៅដោយកនដោយគូរ ។
រនីស្លូតរនីអាឡោះ គិតស្រណោះដល់ជាយា
ថាឥតអស់បក្សា បក្សីសឹងពុំព្រាត់ប្រាស ។
ទុំទឹមទឹមតាំងគូ ម្តេចឥឡូវតែប្អូនមាស
ឃ្លាឃ្លាតទៅទិកស ព្រោះបង់បង់បាត់ពុំយល់ ។
- អ្នកគន់ៗគិតទៅ ព្រះប្អូនពៅថ្មើមនិមិល
ដោរជ្រាបអស្សុផល ស្រក់សស្រាក់ដោយមាគ៌ា ។
លុះស្បូវសាយណ្ហា តាបទៅឯបស្ចិមា
ថ្ងៃនោះអ្នកយាត្រា បានប្រាំពីរយោជន៍កំណត់ ។
ក្អែកនោះធ្វើជាមរណ៍ អង្គអន្តរធានប្រាកដ
នាកាលអស្តង្គត ពន់ព្រលប់ព្រះសុរិយា ។
ព្រះពោធិសត្វថ្ងៃ យល់ក្អែកក្ស័យជីពជន្មា
រងព្រួយព្រះទ័យា ឯងអនាថោថែថប់ ។
- សង្វេគអនិច្ចា ព្រះកគ្រាស្លូតស្ងៀមស្ងប់



កាវនាពីព្រលប់ ដល់យាមបីអ្នកនិទ្រា ។

## បទកុជង្គលីលា

-លុះស្រាងព្រឹកព្រាងសុរិយា រៀងទើបទេព្តា-មួយសឹងសន្ទាន ។
កាឡាកត្តាប្រែប្រាណ ជារុយមួយមាន កំឡាំងស្មើខ្យល់ ។
ហើរហោះផ្លេកផ្លោះមកដល់ ជួយទៅគោតកុល តើពាក្យសួរថា ។
ហៃទ្រង់វរវង្សសោកា មិនមានគ្នីគ្នា ដើរតែឯកអង្គ ។
ចិន្តាប្រាថ្នាហេតុចង់ យាត្រាត្រាច់ត្រង់ ទៅទីឋានណា ។
-ពោធិសត្វវិសេសថា រុយអើយករិយា អង្គអញព្រាត់ទៅ ។
អញមករកតាមសំដៅ ឲ្យដល់នាងនៅ សត្តកុដបុរី ។
រុយឯងចូរឈ្វេងប្រណី ជួយនាំផ្លូវតី អាយឲ្យអញដល់ ។
ឲ្យបានរួមឋានមណ្ឌល នឹងនាងនិមិល ដូចក្តីប្រាថ្នា ។
រុយស្តាប់អ្នកប្រាប់ឆ្លើយថា ដំរខ្ញុំជានា នឹងនាំអ្នកទៅ ។
-ហើយហើរបណ្តើរបមទៅ បរចូលព្រៃជ្រៅ ដោយដានមាគ៌ា ។
ផ្លូវឆ្ងាយចម្ងាយយាត្រា ថ្ងៃនោះគណនា ប្រាំពីរយោជន៍គត់ ។
សុរិយារេលាកំណត់ ម៉ត្តអស្តង្គត អ្នកឈប់និទ្រា ។
រុយនោះចាំពោះធ្វើជា ក្ស័ណក្ស័យមរណា បាត់បង់ជីវី ។

លុះស្រាងបំព្រាងវង្ស សូរ្យសែងអំពី ទីទិសបូព៌ា ។
-អមរិន្ទ្រអង្គឥន្ទកោឡា ប្រែប្រាណជាតិជា អំពិលអំពែក ។
ធីរស្ងួលល្អប្លែក ល្អក្រៃបម្លែក ភ្លឺដូចតាក ។
ផ្តោះផ្តាក(១)ចុះចាកសួគ៌ា មកដល់ព្រះមហា— បុរសរូក្ខ ។
ក្រឡឹងដណ្ដឹងទៅថ្វាត់ ថាអ្នកដើរគាត់ ទៅទីឋានណា ។
គោគកុលទិមិលថ្លៃថ្លា យល់ហើយគិតថា អំពិលអំពែក ។
-ល្អក្រៃប្រពៃចំឡែក ស្ទើរក្ដីផ្អែក នេះសមទេព្ត ។
ទ្រង់រិទ្ធិនិមិតកាឡា ទើបអ្នកឆ្លើយថា ខ្ញុំនឹងឆ្ពោះទៅ ។
ត្រាប់ត្រង់តម្រង់សំដៅ កិរិយាខ្ញុំនៅ សត្តកុដនគរ ។
សក្កាទេវេសាទរ នាំអ្នកចេញចរ ដើរដោយដងព្រៃ ។
ខ្ញុំឃ្លាតសង្វាតពេកក្រៃ រសៀលល្ងាចថ្ងៃ នោះអ្នកដើរដល់ ។
-ស្រះស្រីជាទីជាតជល— សាសាន្តសុខសល់ សម្រាប់ក្សត្រា ។
ព្រះឥន្ទ្រទេវិន្ទ្រផ្តាំថា ចូរអ្នកនិទ្រា នៅនេះសម្រាន្ត ។
ឈប់ស្នេះនៅនេះនឹងមាន ស្រីតាំងពីបុរាណ មកដងគង្គា ។
ទៅស្រង់នូវអង្គធីតា គឺនាងសុខុមា— លន្ទាកល្យាណ ។

១ បញ្ចប់ខ្វះថា ផ្ងោះផ្ងក ។



អ្នកនឹងបានដឹងពិតមាន ជៀងជាក់នឹងបាន ជួបនឹងករិយា ។
ផ្តាំស្រេចសម្តេចឥន្ទ្រា ហោះទៅសួគ៌ា ទិព្វទីលំនៅ ។
គោគកុលទិមិលឥតសៅ ក្រោយព្រះឥន្ទ្រទៅ អ្នកបួលចុះស្រង់ ។
ក្នុងស្រះជ្រៅជ្រះថ្លាធ្វង់ ជំរះព្រះអង្គ ជាសុខសប្បាយ ។
ក្បែរផលក្នុងផលរីកពាយ ព្រលឹតលេចលាយ ទឹងដើមស្គុំស្គុះ ។
សេតុប្បលនីលុប្បលជាលដុះ(១) ល្បូកសរប្រីនប្រុះ ប្រាសប្រាលសឹងផ្កា ។
-ត្រកៀតសឹកសៀតស្ទាបទា ស្ទោមស្ទាបប្រវ៉ា កំពិះពួយព័ន្ធ ។
សួងសាយសាពយដើងមាន់ ក្រុចាប់ណែនណាន់ ត្រកួនកញ្ឆែត ។
មច្ឆារោកអណ្តែត ហក់ហែបហែលហិត រកបរិភោគា ។
អ្នកស្រង់កម្ពុងគង្គា ជម្រះកាយា ស្រេចបរិបូណ៌បាន ។
ឡើងពីស្រះស្រីក្សេមក្សាន្ត ដល់ឆ្នេរមើលមាន សុទ្ធសឹងដើមផ្កា ។
-មហាហង្សត្រយងយុគ្គា ខ្ទឹងក្នុតចម្ប៉ា ចំប៉ុបេកទេស ។
មគ្រ្តលន្តិការកេស នវនួនពិសេស ម្លិះរ័ត្តម្លិះលា ។
ល្បូកត្នែព្រលឹតក្តាំងផា រំដេញមាសចប្បារ រំចេកមាលតី ។

១- ឧប្បល (អ ឋ. ឧប្បលៈ បទុមជាតិ, ព្រលិត, សំពង់ ។ សេតុប្បលៈ ឧប្បលស។ នីលុប្បលៈ ឧប្បលខៀវ ។

រំពាក់បុសនាគនួនស្រី  បន្ទំសុរកី  ស្បៃរឿងរំដួល ។
ដាំផុះច្រើនប្រេះជាជួរ  រៀនកយតាប់គួរ  ដោយឆ្នេរស្រះស្រង់ ។
-អ្នកបានសម្រាន្តផ្ទំក្នុង  ព្រៃប្រែបកំពង់  ឆ្នៀរឆ្នេរស្រះស្រី ។
លុះស្រាន្តព្រឹកព្រានវង្ស  ឯកក្សត្រធិបតី  សត្តកុដពជា ។
ព្រះអង្គស្តេចទ្រង់ចិន្តា  បង្គាប់ទៅថា  នឹងមេពាសី ។
ឲ្យយកក្អមមកបានបី  ទៅដងទឹកពី  ស្រះស្រង់រងថ្វា ។
មកស្រង់នៃអង្គធីតា  ជម្រះកាយា  ផ្សះព្រះកេសី ។
ស្រីគ្នារបរិពារនារី  លុះឮពាក្យពី  ស្តេចទ្រង់បង្គាប់ ។
ម្នីម្នាហៅគ្នាប្រញាប់  កាន់ក្អមផ្គូផ្គាប់  ទូលទុកសិរសា ។
ផ្អៀងផ្អងត្រសងនាំគ្នា  ទាំង៣យាត្រា  ដើរដល់ស្រះស្រង់ ។
ផ្កាស់ព្រស្តុចុះបរទៅក្នុង  ជលសាថ្វាយធំ  ដងដាក់ក្អមពេញ ។
នាំគ្នាលីលាវិលវិញ  យួរយកក្អមមិញ  ដាក់ដល់ឆ្នេរស្រះ ។
-ស្រេចស្រូតទៅផ្ទឹតជម្រះ  មន្ទិលអង្គះ(១)  ក្នុងជលសាសាន្ត ។

## បទកាកគតិ

កាលនោះព្រះពោ-  ធិសត្វសោដោ  អ្នកទៅសម្រាន្ត

១ អង្គ=អវយវៈ, ខ្លួនប្រាណ ។ សរសេរជា «អង្គះ» ដើម្បីឲ្យចួនគឹងពាក្យ «ជម្រះ» ។



ឈប់ខាងឆ្នេរស្រះ  ប្រុងអះយល់ព្រាណ  ស្រីទាំង៣បាន
មកដងគង្គា ។
ទើបអ្នកគន់គិត  អធិដ្ឋានចិត្ត  តាំងឫងទៀងថា
ឱអស់ទេព្រក្ស  អារក្សទេវតា  ឋិតឋានសួគ៌ា
កពគូមិផែនដី ។
គេដះខ្ញុំរក  សូមអ្នកចូលមក  ជួយជាសាក្សី
បើនាងសុខុមា-  លន្ទាទេវី  នឹងបានមេត្រី
ជាគូផងគ្នា ។
សូមឲ្យក្អមនោះ  ធ្ងន់ក្រៃចំពោះ  ដូចថ្មសិលា
កុំឲ្យអស់ស្រី  ទាំង៣នេះណា  លើកក្អមគង្គា
ដល់សិរសីបាន ។
ផ្សងស្រេចពុំលង់  ក្សណៈនោះអស់អង្គ  ស្រីទាំង៣ប្រាណ
ផ្ទឹតទឹកស្រេចស្រាប់  ត្រឡប់វិលថ្កាន  ដល់ឆ្នេរជលសាន្ត
ហើយផ្លាស់ពស្ត្រា ។
ដាក់ដៃថ្នាក់ថ្នម  យួរយកទឹកក្អម  ធ្ងន់ក្រៃមហិមា
ពិតពុំកក្រើក  ព្រួតលើកជួយគ្នា  ក្អមទឹកនោះក៏

នៅនឹងដូចគល់ ។

លុះលាន់មាត់ថា   ពុះខ្លាឡា ៗ   គិតគួរតែឆ្ងល់
ក្អមអ្វីនេះប្លែក   ចំឡែកពេកសល់   អញពុំដែលយល់

ដែលឃើញដូច្នេះ ។

មេមួយជាត់ធំ   ពាលពេញក្រមុំ   ដេរថាមេនេះ
ហានឯងចៀសចេញ   ឲ្យអញឯងអេះ   ធ្ងន់អ្វីប៉ុណ្ណេះ

អញលើកដាក់ឲ្យ ។

ជាតែបុះបាយ   ដណ្តើមប្រញាយ   ដែលក្រយាស្ងាយ
សេសសល់ចំណី   បានធីបែរក្រោយ   កំឡាំងកំសោយ

ដូចគេអត់បាយ ។

ដេរហើយប្រឹងលើក   ពិតពុំកគ្រើក   បែកញើសហូរខ្លាយ
ហាត់ហើយស្រដី   ធ្ងន់អ្វីអម្បាយ   អញគិតមើលឆាយ

ស្មានជាស្រាលទេ ។

មេនោះឆ្លើយវិញ   ថាហានដេរអញ   អ្នកឯងពូកែ
កន្ទ្រលឥតបេ   មានមាត់ស្រួចតែ   រំលឹកដេរគេ

តាមតែនឹងថា ។



កាលនោះពោធិ   យល់មេទាំងបី   លើកក្អមគង្គា
ពុំរួចដាក់ដល់   មណ្ឌលសិរសា   ទើបអ្នកយាត្រា

ចេញចរចៀបទៅ ។

អស់ស្រីផងយល់   មានចិត្តអរសល់   ញោយដៃហើយហៅ
អង្វរចេចា   លេមថាហៃហៅ   កំឡោះល្អញល្អៅ

មានរូបសោភា ។

សូមអ្នកប្រោសព្រួយ   អាសូរមកជួយ   លើកក្អមគង្គា
ដោមដាក់តម្កល់   មណ្ឌលសិរសា   កុំអ្នករួញព

ធុញថាឆាយអាយ ។

ព្រះពោធិសត្វ   មហាបុរសត្ន   លើសលោកទាំងឡាយ
សាកសួរទៅវៃ   ថាហៃនាងអាយ   លំនាំឆោមឆាយ

ហាក់ស្រីអ្នកលើ ។

មកដងទឹកឯង   ប្តីគេតាក់តែង   បង្គាប់ប្រាប់ប្រើ
មកដងទឹកនោះ   ចំពោះបានបើ   ឆ្ងួតផឹកប្តីធ្វើ

អ្វីប្រាយប្រាប់ ។

សាវដៃទាំងបី   ព្ទពាក្យពោធិ-   សត្វសួរសាស័ព្ទ

ទើបមេម្ដាយឆ្លើយ  អ្នកអើយអ្នកស្ដាប់  ខ្ញុំនឹងប្រាយប្រាប់
ឲ្យអ្នកដឹងជាន ។

ផ្ចិតកាជបុត្រី  ក្សត្រាធិបតី  ឥស្សូរផ្ទើនក្ងាន
ព្រះឥន្ទបមភៅ  យកទៅឲ្យមាន  ប្ដីនៅពាក-
ណាសីនគរ ។

នាងនៅពុំសុខ  អំពល់ជាទុក្ខ  ទើបនាងបាកបរ
វិលវិញផ្ដោះមក  រំសេវកព្រះវរ-  បិតាក្ដួរ
នូវព្រះមាតា ។

ទើបក្សត្រទូត្តម  គ្រាស់ប្រើយើងខ្ញុំ  មកជូនគង្គា
យកទៅជម្រះ  ផ្សះព្រះកេសា  នៃនាងនាថជា
បុត្រីកល្យាណ ។

ពោធិសត្វស្ដាប់  សាវ៉ៃប្រាយប្រាប់  ដឹងដើមពិតមាន
ថានាងមកដល់  មណ្ឌលទីឋាន  ត្រើសព្រះទ័យក្សាន្ត
សោមនស្សាសល់ ។

អ្នកយកព្រះទម្រង់  មួយមកដាក់ក្នុង  ក្អមមាសនិមល
មិនឲ្យអស់ស្រី  ពាសីធន់យល់  ទៀតទើបទសពល



អធិដ្ឋានថា ។

បើមានស្រប់ស្រន់  ជម្រះអស់អ-  ង្គកាយធីតា
សូមឲ្យទម្រង់  បញ្ជូនថ្លៃថ្លា  ចូលម្រាមហត្ថា
ដូចគេបំពាក់ ។

តាំងចិត្តសច្ចា  ផ្សងស្រេចព្រះមហា-  បុរសចមចក្រ
យួរយកទឹកក្អម  ដាក់ថ្មហើយអ្នក  ស្ទបស្ទួយជល់ដាក់
លើក្បាលពាសី ។

សាវ៉ៃត្រេកអរ  អំពើថ្ងៃបថូរ  លាព្រះពោធិ
ចូលទឹកក្អមទៅ  លំនៅចិត្តទី  នៃនាងនារី
ដល់ស្រេចថ្វាក់ថ្វាយ ។

ទើបរាជធីតា  ស្រប់ស្រន់គង្គា  ជំរះព្រះកាយ
ផ្សះព្រះកេសា  ហត្ថាពណ្ណរាយ  ជ្រួយជ្រងសិរសាយ
កេសីវល័ក្ខណ៍ ។

សាវ៉ៃស្ទួយក្អម  មាសម័យថ្នាក់ថ្នម  លើកឡើងផ្ទៀងចាក់
ទឹកតាំងព្រះទម្រង់  នៅក្នុងក្អមធ្លាក់  ដូចគេបំពាក់
ព្រះហស្តក្សត្រី ។

នាងទតយល់ជាក់ ដឹងដើមរៀមរ៉ែ ជាព្រះស្វាមី
តាមមកជួបដល់ មណ្ឌលស្រះស្រី នាងនាថនារី
ត្រេកសោមនស្សា ។
អរឯងពេកពន់ នាងត្រាស់សួរដ- ណ្ដឹងសាវ៉ៃជា
ហាងទៅដងទឹក ពីព្រឹកសុរិយា ទៅលេងឯណា
បាត់យូរអម្បាយ ។
ហើយហាងឯងបាន ចិញ្ចៀនមាសមាន ត្បូងរត្នពណ្ណរាយ
ដាក់ក្នុងទឹកក្អម លើកថ្នមមកថ្វាយ ចូរហាងនិយាយ
បានពីនរណា ។
សាវ៉ៃបង្គំ ទូលថាកាលខ្ញុំ ទៅដងគង្គា
អំពីកំពង់ ស្រះស្រង់ជលសា មានហេតុយល់ជា
អស្ចារ្យពេកពន់ ។
បានជាបាត់យូរ សូមម្ចាស់អាសូរ ឲ្យគង់ជីពជន្ម
ក្អមទឹកស្រាលទេ ម្ដេចប្រែជាធ្ងន់ ធ្ងន់ក្រៃពេកពន់
ខ្ញុំមិនដែលយល់ ។
ព្រួតគ្នាជួយលើក មិនមានកក្រើក នៅនឹងដូចគល់



រួយរសាយដៃ គាប់ថៃបានយល់ ប្រុសមួយនិម៉ល
កំឡោះសោភា ។
ដើរមកប្រទះ យើងខ្ញុំសំពះ អង្វរគ្រប់គ្នា
គាត់មកជួយថ្នម លើកក្អមគង្គា ដាក់ដល់សិរសា
ខ្ញុំទាំង ៣ នាក់ ។
ទើបខ្ញុំទូលយក ក្អមទឹកនោះមក ថ្វាយម្ចាស់ទ្រង់លក្ខណ៍
ចិញ្ចៀននេះឯង ខ្ញុំក្រែងតែអ្នក ប្រុសនោះលបដាក់
មកក្នុងគង្គា ។
នាងស្ដាប់សំដី ពាក្យពីទាសី នាងជ្រាបជាក់ជា
ព្រះស្វាមីមក តាមរកធីតា ត្រេកសោមនស្សា
អរេតថ្លឹងថ្លែង ។
ព្រះឧស្ឋទិព្វគន់ ត្រាស់ទ្រង់ចំអន់ ថាអស់ហាងឯង
ពើពាក្យមាយា មុសាឥតក្រែង នាំគ្នាដើរលេង
ទៅរកសាហាយ ។
ជួបជួនប្រុសប្រាណ ប្រឡែងគ្នាបាន កៀកកនិយាយ
អស់ចិត្តទើបយក ទឹកមកថ្វាត់ថ្វាយ កកូតប្រាប់ប្រាយ

ជាក្អមទឹកជូន ។

សាវ៉ៃជតាំងកិត ទូលជាបពិត្រ ម្ចាស់ថ្លៃមានបុណ្យ
ខ្ញុំទូលពាំនិត ពាក្យពិតពេកពន់ ពិតជាក្អមជូន
ពុំហានមុសា ។

នាងនាថកក់ស្រង់ ស្រេចក្បត្រៃទ្រង់ អម្ពរពស្ត្រា
គាក់តែងព្រះអង្គ ហើយនាងលីលា ឡើងគាល់បិតា-
ពិភពផ្ទើនថ្កល់ ។

ដល់ស្រេចនាងថ្វាយ បុស្បក្តិជកាយ(១) ករកបកោមល(២)
ទូលជាផ្សិតបី ស្វាមីនិមិល តាមខ្ញុំមកដល់
ស្រះស្រង់ជៀនជាក់ ។

ដីងដោយពាសី ទៅផងទឹកពី ស្រះផ្កូចនិងអ្នក

១– ក្លាយមកពីពាក្យ បុស្ប "ផ្កា" សង្គបន្ទ័ន (ហៅក្លាយថា ក្បន្តិប) = ឧប្បលមួយយ៉ាង ផ្កាតូចៗ មានត្របក ៣ ស្រទាប់, មានព័ណក្រហមច្រាល (ឈ្មោះច្រាល) ។

២–នៃប្រកបដោយផ្កាកោមល(ឈូក) ។ ពាក្យទាំងពីរឃ្លានេះ ជាអត្ថប្បដិរូប គឺជាពាក្យប្រៀបធៀបកាយរបស់ខ្លួន នៃលបង្អោនទៅនោះ ទុកទ្វីបជាដើមឈូក និងម្រាមដៃនៃលលើកឡើងគាក់ផ្ទុំប្រណម្យសំពះនោះ ទុកទ្វីបជាក្រពុំផ្កាឈូក ។



យកព្រះទម្រង់ ត្តផ្ទង់ទំលាក់ កូនក្អមដែលដាក់
ទឹកទូលឡើងមក ។

ខ្ញុំផ្ទុតគង្គា ទើបយកហត្ថា ជ្រងជ្រួយសក់សឹក
ចិញ្ចៀនទម្រង់ ដោយកូនទឹកមក ដូចគេពាក់ប្រក
នៅម្រាមកូនដៃ ។

ខ្ញុំមើលស្គាល់ជាក់ ចិញ្ចៀនដែលពាក់ ពិតពុំសង្ស័យ
ទើបខ្ញុំចរចូល មកទូលក្សត្រថ្លៃ ឲ្យជ្រាបព្រះទ័យ
តាមតែមេត្តា ។

ស្តេចស្តាប់ទំនូល ពជបុត្រទូល ពីព្រះសុណិសា
មកដល់ស្រះស្រង់ ស្តេចទ្រង់ចិន្តា ត្រេកអរសោមនស្សសា-
ទរទើបបង្គាប់ ។

ជាហៃសេនា តាំង៤ម្ហូមា រួសរៀបប្រដាប់
ក្រែព្រះពជយាន មាសមានសម្រាប់ គ្រឿងគូសផ្គូផ្គាប់
គ្រឿងតារ(១)ពស្ត្រា ។

ឲ្យល្អសមគួរ បេញទៅទទួល យកកូនប្រសា
អញ្ជើញពីកពង់ ស្រះស្រង់ដេថ្វា នាំមកម្ហូមា

១– ក្លាយមកពី អម្ពរ ។

កុំឲ្យផ្សេងផ្សេង ។

សេនាស្ដែងស្ដាប់ ស្ដេចទ្រង់បង្គាប់ ប្រាប់គ្នាពុំលង់
រៀបគ្រឿងប្រដាប់ សម្រាប់ស្ដេចទ្រង់ នានាំគ្រាប់គ្រង់
ដល់ខ្នោរស្រះស្រី ។

យល់មហាបុរស រត្នរូបស្រៀវស្រស់ លើសលែងលោកិយ
ទើបអស់សេនា យោធាមន្ត្រី ចរចូលអភិ-
វាទវរវន្ទា ។

ទូលថាសូមទាន ពីមហាក្សត្រក្សាន្ត ជាព្រះបិតា-
ធិរាជឧត្ដម ប្រើខ្ញុំករុណា យកព្រះកូសា
ព្រះពស្ត្រដែលទ្រង់ ។

ទ្រង់ព្រះរាជទាន មកអម្ចាស់មាន រូបរត្នវរ-
ផ្សាសក្ដិស្មស្ដិ៍សម ឲ្យអម្ចាស់ទ្រង់ ស្រេចហើយឲ្យគង់
លើរាជយានទៅ ។

ព្រះពោធិសត្វ មហាបុរសរត្ន វិសេសចមទៅ
ទទួលពស្ត្រា កូសាមាសឆ្អៅ ល្អះល្អឥតសៅ
អ្នកយកមកទ្រង់ ។



សក្តិសមសោភា ហាក់អង្គទេព្តា យាងយាសឡើងគង់
លើព្រះរាជយាន- មាសមានពលពង្ស សេនាចតុរង្គ
ហែៗរៀងកាយ ។

បើកបាំងក្លស់ក្លុំ ខ្ពង់ខ្ពស់ត្រសុំ ត្រសាក់ត្រសាយ
ត្រសៀករំហើយ រំភើយព្រះពាយ ទៅទៀបបន្ទាយ
រាជវាំងក្សត្រា ។

អ្នកចរចុះថ្កាន ពីព្រះរាជយាន យាងយាសលីលា
ឡើងលុះលើឋាន ពិមានរាជា គ្រញូគ្រាបវន្ទា
ប្រណម្យនិត្យនៅ ។

កាលនោះក្សត្រា ជាព្រះបិតា គយគន់មើលទៅ
យល់ពោធិសត្វ រូបរត្នល្អញល្អៅ ព្រះភក្ត្រឥតសៅ-
ហ្មងមានរស្មី ។

ដូចចន្ទ្រចែងចាំង ក្ដីផ្ដុកអស់ចាំង អាកាសឧតី
ឥតនរអ្នកស្មើ លើសលើលោកិយ ប្រុសនៅដែនដី
ផ្ទាប់ផ្ទឹមមិនបាន ។

ទ្រង់ព្រះចិន្តា ក្នុងព្រះទ័យថា ឱបុត្របុកណ

សំណាងកូនអញ សំឡាញ់មកបាន ស្វាមីមិញមាន
គោមគាយសោកា ។
គាប់គួរជាគូ ល្អល្អះត្រឹមត្រូវ ស័ក្តិសមនឹងគ្នា
ស្តេចគិតឯងអរ សាទរមហិមា ត្រេកត្រាស់សួរថា
ហៃបុត្រពិសី ។
អាពុកចង់ដឹង ចង់ជ្រាបដំណឹង ដំណើរអំពី
ព្រហ្មទត្តពាលា ហៅបារទៅថ្វី បានជាបុត្រី
វត់មកតើម្តេច ។
កាលនោះព្រះពង្ស ពូជពោធិវ- ង្សាស័ក្តិសពេជ្រ
ទូនអង្គបង្គំ ប្រណម្យស្រួលស្រេច ទូលទៅសម្តេច
ព្រះវរបិតា ។
ពីនាងនាថវត់ ព្រោះព្រះព្រហ្មទត្ត កាចគិតឫស្យា
គ្រាស់ឲ្យមកហៅ ខ្ញុំទៅគោក្គា សឹងស៊ុតមានពា
លាយនឹងចំណី ។
ខ្ញុំបរគោក្គា ស្រេចហើយលុតលា មកមណ្ឌបទី
វកនាងពុំយល់ សោកសល់សែនទ្វី ដឹងដើមសេចក្តី



ដោយក្តែប្រាប់ប្រាយ ។
ថានាងកល្យាណ នឹងនៅពុំក្សាន្ត វត់មកស្រុកអាយ
ទើបខ្ញុំត្រាច់មក តាមវកគោមគាយ ឆ្លងដលសាសាយ
រួចដល់ត្រើយត្រាណ ។
ទើបក្តែមរណា គ្នាគនាំមាគា ប្រាំពីរយោជន៍បាន
គ្នាគនោះសោតស្លាប់ ស្រេចស្រាប់តែមាន ក្អែកនាំផ្លូវបាន
ប្រាំពីរយោជន៍សល់ ។
ក្អែកនោះសោតស្លាប់ មានរុយមួយប្រាប់ ណែនាំដើរដល់
ប្រាំពីរយោជន៍ឆ្ងាយ ចម្ងាយទុពិល រុយស្លាប់ទៀតយល់
អំពិលអំពែក ។
មួយមានធរី រុងរឿងរស្មី អស្ចារ្យចំឡែក
ល្អដូចផ្កាយព្រឹក ភ្លឺផ្លេកពន់ពេក កណ្តាលផ្ទៃមេឃ
លើសលែងតារា ។
នាំខ្ញុំត្រាច់ត្រង់ មកដល់ស្រះស្រង់ ទ្រង់ព្រះករុណា-
ពិសេសហើយហោះ ផ្តោះទៅសួគ៌ា សមអង្គទេវ
មែនមិនជាទេ ។

បពិត្រអម្ចាស់ ខ្ញុំលំបាកណាស់ កាលដើរដោយព្រៃ
ម្នាក់ឯងពុំគិត ជីវិតក្សិណក្ស័យ សូមក្រាបព្រះទ័យ
ពុំចេះមេត្តា ។
ស្តេចស្តាប់ពាក្យពី ពូជពង្សពោធិ៍ ទូលទើបក្សត្រា
ក្រាបសព្វសេចក្តី ហើយស្តេចអនិច្ចា សង្វេគចិន្តា
អាណិតពោធិ៍ ។
ទើបស្តេចត្រាស់ឲ្យ រៀបក្រយាស្ងោយ ភោជ្យកស្តុពិសី
ពិសាត្រកាល អាហារថ្មោងថ្មី មកឲ្យពោធិ-
សត្វសោយស្កប់ស្កល់ ។
កាលនោះក្សត្រា ទ្រង់ព្រះចិន្តា ដោយព្រះយោបល់
ជាបុត្រប្រសា សោភានិមិល មានរឹទ្ធិពល
ឫតរឹទ្ធិ ។
គិតគួរតែអញ យកធ្នូឲ្យបាញ់ លេងលន់បារមី
ទើបបើកព្រះសូរ បន្ទូលទៅខ្ទី ជាហែមន្ត្រី
កំណាន់រក្សា ។
ចូរហៅចរទៅ យកធ្នូសិល្បនៅ សរស័ក្តិថ្លៃថ្លា



សែនមកឲ្យឆាប់ ប្រញាប់ម្នីម្នា មន្ត្រីលុតលា
ចុះចរស្វែសពាន់ ។
ប្រើនាយប្រាប់ពល ហៅគ្នារចល់ ចូលមកបន្ទាន់
កាន់ឈើស្នែងទៅ សែនធ្នូកំណាន់ រត់ស្វែរទ្វាន
ដល់ថ្វាយក្សត្រា ។
ស្តេចទតទៅយល់ ធ្នូជ័យមកដល់ បើកបន្ទូលថា
ហៃចៅគោត្រកុល និមិលសោភា កូនអើយចូរបា
បាញ់ធ្នូនេះមើល ។
ចង់ដឹងរឹទ្ធី ពាលពលបារមី បាបុត្រប្រសើរ
លេងលន់ចេស្តា ឲ្យអាពុកមើល ឲ្យដឹងដំណើរ
កាលគ្រានេះម្តង ។

## បទពំនោល

ព្រះពោធិសត្វប្រាស់ប្បន់ ក្រញូក្រាបកបរង ទទួលព្រះរាជទង្ការ ។
លុតលាយាត្រាត្រអាល ទៅដល់កណ្តាល ទីមុខព្រះលានក្សត្រា ។
ទើបអ្នកឈរឈានជហត្ថា យកធ្នូសរថ្វា គ្រវាសគ្រវីលេងលង ។
យល់ហាក់ស្រាលក្រៃកន្ទុន ដូចកលស្រើផង កាន់ជងដំពេចសំឡី ។

-វាយវាត់ដំឡើងឆាប់ខ្មី គ្មានគិតភ័យអ្វី ទើបយកសរមកផ្គូផ្គាប់ ៗ
បែរបាញ់ចេញទៅពុស័ព្ទ សូរសរហាក់ផ្អាប់ ក្រឡាប់តាំងកូមិកពការ ៗ
ព្រួញទៅដល់ក្រៅចក្រពាល កំពែងចក្រវាល ហាក់ដូចនឹងផ្កាប់ព្រោមខ្ទេចៗ
ពុះពោរផងផោរសមុទ្រ សុមេរុបពិត កក្រើករំពើកញាប់ញ័រ ៗ
លាន់ព្រះខ្ទរអស្ចារ្យ រំពងខ្ទរខ្ទារ ដូចសែនរន្ទះគណនា ៗ
-អស់កត្រូវគិតភ័យតក្កមា លុះលាន់មាត់ថា ឱះអះពះស្លាប់នេះម្តង ៗ
ស័ព្ទអ្វីព្រៃក្រកន្ទង ស្អៀស្អេះដំពង ស្មើនឹងបែកខ្ទុងកាំមា ៗ
កន្ត្រខ្ទះដឹងហើយប្រាប់ថា ដ្បិតព្រះករុណា ក្សត្រាធិកដថ្កើងថ្កាន ៗ
បាញ់ធ្នូទៅមុខព្រះលាន ការណអើយកុំការណ គិតភ័យខ្លាចក្សយជន្មា ៗ
អស់មុខមន្ត្រីយោធា យង់យល់ចេស្តា— ទុភាពព្រះអង្គលើសក្រៃ ៗ
-សឹងកោតស្ញប់ស្ញែងទទៃ ត្រើសព្រមជួយជ័យ ចំរើនព្រះពរអឹងអឹង ៗ
សិល្បសរស័ក្តិសោតវិលវឹង វិលមកនៅទីង បំពង់ដែលដាក់និត្យនៅ ៗ
ទើបអ្នកលីលាឡើងទៅ បង្គំគាល់ហៅ នៃព្រះជនកក្សត្រា ៗ
ស្តេចយល់វិទ្ធពលចេស្តា បុណ្យបុត្រប្រសា ប្រសើរប្រសប់សិល្បសៃយៗ
ព្រួចព្រឺព្រើសព្រះកត្រ្តថ្លៃ ត្រេកត្រូវព្រះទ័យ វិតៅពឹងរេកល ៗ
-ដោយព្រះទិព្វញាណយោបល់ ចង់ល្បងឲ្យយល់ អំពល់អំពើកម្រៗ
ឲ្យយករទេះពីរមក មួយដាក់គ្រាប់ល្ង មួយទុកទទេនិត្យនៅ ៗ



ទើបស្តេចបើកបន្ទូលទៅ ត្រាស់ថាហៃហៅ គោត្តគុលជាបុត្រសំឡាញ់ៗ
ចូរបាចសព្វហាក់អស់អញ រើសគ្រាប់ល្ងចេញ ពីក្នុងរទេះនេះទៅ ៗ
ដាក់រទេះទទេនៅ ម្តងមួយគ្រាប់ទៅ ឲ្យអស់ក្នុងថ្ងៃនេះថ្ងាត ៗ
-ឯអង្គពុទ្ធពង្សត្រូវត្រា ក្រញាក្រាបប្រណិប័តន៍ ទទួលព្រះរាជអាជ្ញាៗ
អ្នកគិតតាំងចិត្តចិន្តា ប្រណិធានសច្ចា នឹកដល់ព្រះឥន្ទធិបតី ៗ
ជាទីអស់បុណ្យបារមី អញសាងអំពី ម្តងអសង្ខេយ្យា ៗ
បើអញនឹងបានត្រាស់ជា អង្គព្រះសម្មា— សម្ពុទ្ធប្រាកដទៀងទាត់ ៗ
ឆ្លាស់ឆ្លងការកូមិកពវដ្ត— សង្សារនាំសត្វ ដាក់ដល់នគរនិព្វាន ៗ
-សូមឲ្យព្រះឥន្ទ្រហោះធ្យាន មកជួយឲ្យបាន សម្រេចដូចក្តីប្រាថ្នា ៗ
តេជះហេតុបារមីគា ពន្លកសាស្តា ក្តៅដល់មណ្ឌលកម្ពល ៗ
សិលាអាសនាថ្កើងថ្កល់ ទិព្វទីមណ្ឌល សម្តេចអមរិន្ទឥន្ទ្រា ៗ
បានបែរបើកទិព្វចក្ខុ យង់យល់ព្រះមហា បុរសព្រួយព្រះហឫទ័យ ៗ
ស្តេចហោះចុះពាក់ហាននៃត្រ— ត្រឹង្សត្រាប់ត្រង់ឭ បុរសក្តុងរាជា ៗ
-ប្រញាប់ប្រាណប្រែងប្រែកាឡា និមិតកាយា ជាក់ជាស្រមោចខ្មៅខ្ចល ៗ
ពេញពាសដេរដាសទគ្គល ពាំល្ងជាជួរ ជញ្ជូនពីរទេះចេញ ៗ
ដាក់ទៅរទេះមួយមិញ មួយរំពេចពេញ ពុំសល់ដល់មួយគ្រាប់នៅ ៗ
ព្រះវរបិតាចមរេចៅ ស្តែងស្តេចទតទៅ យល់ជាអស្ចារ្យពេកពន់ ៗ

សេនាយោធាមុខម- ន្ត្រីប្រជាជន យល់ហើយសឹងកោតបេស្កា ។
-ស្វែងបុណ្យស្វែងបារមីគា សឹងឲ្យស័ព្ទសា- ធុការចំរើនព្រះពរ ។
កាលនោះសម្តេចព្រះវរ- បិតាសាទរ ព្រះអង្គទ្រង់ព្រះចិន្តា ។
បង់លបង់ល្បងប្រាជ្ញា បុណ្យបុត្រប្រុសា ប្រសើរឲ្យបានបីដង ។
ស្តេចប្រើនាយព្រះក្រាលផង ក្រាលព្រំបៀមចង រនាំងបាំងព្រះសន្ធិយា ។
ស្រេចឲ្យអស់អង្គធីតា ប្រាំពីរអង្គា លីលាឡើងមកគាល់គង់ ។
-រៀបរៀងកល់កាយពីក្នុង បន្ទប់តែចុង ម្រាមព្រះហស្តមកក្រៅ ។
ស្តែងស្តេចបើកបន្ទូលទៅ ត្រាស់ថាហៃហៅ គោត្រកុលជាបុត្រស្នេហា ។
បាមើលម្រាមហត្ថា កិរិយានៃបា ត្រង់ណាចាប់ឲ្យត្រូវត្រង់ ។
ព្រះពោធិសត្វវរវង្ស ស្តាប់ស្តេចត្រាស់ទ្រង់ បង្គាប់ឲ្យចាប់ហត្ថា ។
អ្នកទតទៅយល់ដូចគ្នា ពុំស្គាល់ត្រង់ណា ជាក់ជាព្រះហស្តក្សត្រី ។
-តេជះហេតុព្រះបារមី ទើបព្រះកោសិយ កាឡាអង្គាគួរគាប់ ។
ជារុយមាសមួយមកផ្ទាប់ ខាងព្រះស្រោតស្រាប់ ខ្សឹបប្រាប់ព្រះពង្សពុទ្ធា ។
បើអ្នកពុំស្គាល់ហត្ថា នៃនាងសុខុមា- លក្ខាទេវីវរវង្ស ។
ឃើញទៅចាំនៅនាចុង ម្រាមចាប់ត្រង់ នោះឯងព្រះហស្តធីតា ។
ប្រាប់ហើយទៅចាំមុមា ទើបអ្នកប្រាជ្ញ ចាប់តាមតែរុយទៅចាំ ។



-អ្នកទូលក្សត្រថ្លៃឧត្តម ម្រាមករិយាខ្ញុំ នេះឯងប្រាកដជៀងជាក់ ។
នាងសុខុមាវរលក្ខណ៍ ចេញមកសំណាក់ សំណេះសំណាលសាកសួរ ។
ខុនអង្គាគង់គាល់គួរ បិតាស្តេចស្រួល ព្រះទ័យត្រេកសោមនស្សា ។

## បទកាកគតិ

កាលនោះព្រះបាទ សត្តកុដកដជាតិ ជាព្រះបិតា
យល់តេជតេជះ តបះរិទ្ធា បុណ្យបុត្រប្រុសា
ប្រសើរពេកក្រៃ ។
ត្រកាលកន្ទុន រម្ទឹងប្រុសផង នីរអ្នកដទៃ
ណាទឹងផ្ទឹមបាន ក្សត្រក្សាន្តជៀសជ័យ ត្រេកត្រាស់ថាហៃ
មន្ត្រីសេនា ។
អញនឹងរើក- សេកកពជបុត្រី នៅបុត្រប្រុសា
សេពសោយរាជ្យស្នង គ្រប់គ្រងសីមា ចូរអស់គ្រប់គ្នា
រួសរៀបរណ្តាប់ ។
តាក់តែងក្នាក់ផ្ការ រេបណ្ណាការ គាប់គួរដោយច្បាប់
មន្ត្រីអាមាត្យ បត់បាទទូនស្តាប់ ទទួលបង្គាប់
បង្គំលុតលា ។

បរចុះដើរដល់ ទីឋានបណ្ដូល ព្រមព្រាប់គ្នីគ្នា
ស្លូរកេកស្ដុការ ដោយនារអាត្មា ប្រដាប់ប្រដា
ប្រញាប់ខ្វល់ខ្វាយ ។
ខ្វះនៅស្រុកស្រែ ស្លូរកេបន្ទៃ សណ្ដែកពពាយ
ម្នាស់ននោងនៅ រពៅខ្ទីខ្វាយ ខ្ទៀមខ្ទឹមគូផាយ
ត្រឡាបម្រេចខ្ញី ។
ម្រះម្លូសទុំ ក្រសាំងទំហាំ លីងលាក់ក័កដីរ
ក្រូបគ្រាប់លើង រំដេងផ្ទេរផ្ទីរ សណ្ដែកកុនដី
រមៀតម្រះព្រៅ ។
ផឡឹកស្វឹកគ្រែ ត្រសក់ស្តីស្តែ ឃ្លោកល្ហុងត្រប់ក្រៅ
បេកឥតក្រយូង អំបូងខ្លូនខ្មៅ បេកផ្កាអំពៅ
អំពិលក្រសាំង ។
ខ្វះរកដំឡូង ឈាមមាន់ត្នោតដូង ដំឡូងបារាំង
ដំឡូងដៃខ្លា ពុទ្រាខ្នុរណាំង ក្តិបស្វាយទំពាំង–
ដូរដីសំពៅ ។
១-រកបានសព្វគ្រប់ ដោយមុខនារសេព្វ មន្ត្រីក្នុងក្រៅ



ទើបប្រើអាជ្ញា យាត្រាប្រាប់ហៅ ខុនណាងឲ្យទៅ
អង្គុយពេងថែម ។
ខុនណាងខ្លួនខ្វះ សម្បុរស្រដ្រះ ខ្វះខ្មៅស្រអែម
មុខមាត់ខឹមរេម ញញឹមញញែម លាបប្រេងរលេម
រលោងស្ទើរស្រក់ ។
ខ្វះដោះសណ្ដាយ មុខស្រស់រីកពាយ យកស្ទួតសិតសក់
លាបប្រេងផាត់ម្សៅ មើលទៅកញ្ចក់ ក្រែងខ្លួនអាក្រក់
ប្ដីមិនស្រឡាញ់ ។
នាងខ្វះដោះកំ ពាក់អាវសសម សក់វែងខ្មៅខ្មាញ់
ស្លៀកខៀនហ៊ានស ផ្កាស្រកាលេញ យាងយាសបរបេញ
ពីផ្ទះអាត្មា ។
នាងខ្វះដោះញ ពាក់អាវព្រែស ដណ្ដប់កាសាវ
ស្លៀកសំពត់ហូល ដរបូខៀនផ្កា ផាត់ម្សៅគន្ធា
បញ្ចើអង្គអាត្មា ។
នាងខ្វះញ៉ែងញ៉ង បួងបត់សក់បង រូបរាងស្អាតបាត
ថ្ពាល់ម៉ដ្ឋប៉ូវ ស្លៀកហូលសុទ្ធគាត បរបូលប្រាសាទ